# ទម្រង់ប្រាសាទបែបផាម្សនានៅក្នុងសិល្បៈខ្មែរ

កាលពីអត្ថបទមុនខ្ញុំបានបង្ហាញម្ដងហើយពីទម្រង់ប្រាសាទមួយប្រភេទដែលខ្មែរទទួលឥទ្ធិពលពីសិល្បៈឥណ្ឌា គឺប្រាសាទបែបសាលា ឬវលភី។[១] សម្រាប់អត្ថបទនេះខ្ញុំនឹងបង្ហាញទម្រង់ប្រាសាទមួយប្រភេទទៀតដែលជាងនៅសម័យបុរាណទំនងជាបានទទួលឥទ្ធិពលពីសិល្បៈឥណ្ឌាដែរ នោះគឺទម្រង់ប្រាសាទបែប ផាម្សនា (Phāmsanā)។ ពាក្យថា "ផាម្សនា" ជាពាក្យបច្ចេកទេសហៅតាមភាសាសំស្ក្រឹត ចំណែកភាសាអូរិយាវិញហៅសំណង់ប្រភេទនេះថា "បិឍាទេឧល" (Piḍhā Deul)។[២]

**ប្រាសាទបែបផាម្សនា** ជាប្រភេទសំណង់មានរាងបួនជ្រុងស្មើ មានដំបូលសំប៉ែតត្រួតគ្នាច្រើនថ្នាក់យ៉ាងញឹក ថ្នាក់នីមួយៗរៀងគ្នាជាលំដាប់ពីធំទៅតូចៗ នៅក្នុងស្ថាបត្យកម្មឥណ្ឌាហៅដំបូលសំប៉ែតនេះថា **កបុត** (Kaputa) តែសម្រាប់សិល្បៈខ្មែរវិញគេច្រើនហៅថ្នាក់នៃដំបូលទាំងនេះហៅថា **រូត**។[៣] នៅតាមកបុតនៃជាន់និមួយៗ មានលម្អជាគូឱ[៤]តូចៗរៀងគ្នាជាជួរ។ លក្ខណៈពិសេសរបស់ប្រាសាទបែបផាម្សនាគឺ រាងខាងក្រៅនៃដំបូលទាំងមូលមានលក្ខណៈជារូបត្រីកោណ ហើយផ្នែកកំពូកនិយមលម្អដោយអាមលក ឬ**ស្តូបិកា** (Stūpikā) (រូបលេខ១)។ ទម្រង់ប្រាសាទនេះនិយមទាំងនៅឥណ្ឌាភាគខាងជើង និងផ្នែកខាងលិចនៃឥណ្ឌាភាគខាងត្បូង ដោយនៅឥណ្ឌាខាងជើងចាប់ផ្ដើមកើតឡើងនៅក្នុងសិល្បៈគុប្តៈ ចំណែកឥណ្ឌាខាងត្បូងវិញចាប់ផ្ដើមមាននៅក្នុងសិល្បៈចាលុក្យៈ។[៥]

[១] សូមអានបន្ថែមនៅ៖ https://ams.com.kh/khmercivilization/detail/20468

[២] Adam Hardy 2007: 111& 123.

[៣] ព្រាប ចាន់ម៉ារ៉ា ២០១២: ៦៨។

[៤] នៅក្នុងសិល្បៈខ្មែរជួនកាលហៅថាកូនបង្អួច សូមអាន៖ ព្រាប ចាន់ម៉ារ៉ា ២០១២: ៥២៥៣-។

[៥] Chedha Tingsanchali 2022: 87.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ១៖ ប្រាសាទ Pinākapāṇi នៃក្រុមប្រាសាទ Mahakuta (រូបថត៖ Ajeya Vajpayee)

សម្រាប់ស្ថាបត្យកម្មខ្មែរវិញ ការសាងប្រាសាទដែលមានទម្រង់បែបផាម្សនា យើងប្រទះឃើញតាំងពីមុនសម័យអង្គរមកម្ល៉េះ។ ជាក់ស្តែងប្រាសាទមួយចំនួននៅតំបន់សម្បូរព្រៃគុក ប្រាសាទព្រះធាតុតូចនៅត្បូងឃ្មុំ ប្រាសាទភ្នំឈ្វោកនៅខេត្តកំពត ប្រាសាទតូចនៅកំពង់លែងជាដើម។ ប្រាសាទព្រះធាតុតូចនៅខេត្តត្បូងឃ្មុំនិងប្រាសាទគុកព្រះធាតុនៅហាន់ជ័យមានលក្ខណៈសំណង់ស្របតាមប្រាសាទបែបផាម្សានយ៉ាងខ្លាំង ពោលគឺ ជាប្រាសាទមានរាងបួនជ្រុងស្មើរស្មើគ្នា ដំបូលមានលក្ខណៈសំប៉ែតត្រួតគ្នាច្រើនជាន់ តាមជាន់នីមួយៗ មានលម្អដោយគូឌុតូចៗរៀងគ្នាជាជួរ។ ដោយឡែកផ្នែកខាងលើបង្អស់នៃដំបូលរបស់ប្រាសាទព្រះធាតុតូចបានបាក់បែកអស់ ទើបធ្វើឱ្យយើងមិនអាចដឹងពីលក្ខណរបស់លើដំបូលឡើយ (រូបលេខ២២)។ តែបើយើងប្រៀបធៀបលក្ខណៈដំបូលរបស់ប្រាសាទព្រះធាតុតូចជាមួយប្រាសាទគុកព្រះធាតុនៅភ្នំហាន់ជ័យវិញឃើញថា ប្រហែលជាមានលក្ខណៈដូចគ្នាគឺត្រង់កំពូលលម្អដោយកលស (រូបលេខ២៣)។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ២៤៖ ក្រុមប្រាសាទព្រះធាតុតូច (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ៣៖ ប្រាសាទគុកព្រះធាតុ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

លក្ខណៈពិសេសរបស់ទម្រង់ប្រាសាទបែបផាម្សនានៅក្នុងសិល្បៈខ្មែរនៅមុនសម័យអង្គរគឺ ការធ្វើប្រាសាទបែបផាម្សនាឱ្យមានរាងប្រាំបីជ្រុង (រូបលេខ២៤) លក្ខណៈនេះ គឺខុសប្លែកពីសំណង់នៅឥណ្ឌាដែលធ្វើប្រាសាទបែបផាម្សនាមានរាងបួនជ្រុងជានិច្ច។ ហើយការធ្វើប្រាសាទបែបផាម្សនាឱ្យមានរាងប្រាំបីជ្រុងបែបនេះក៏មិនប្រទះឃើញមាននៅក្នុងសិល្បៈផ្សេងនៃអាស៊ីអាគ្នេយ៍ដែរ។[៦] យ៉ាងណាក្តីប្រាសាទប្រាំបីជ្រុងបែបនេះនិយមតែនៅសម័យមុនអង្គរប៉ុណ្ណោះ។



រូបលេខ២៤៖ ប្រាសាទN7 (រូបថត៖ ក្រសួងព័ត៌មាន)

---

[៦] Chedha Tingsanchali 2022: 172-176.

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

នៅក្នុងសិល្បៈខ្មែរ ការសាងប្រាសាទបែបផាម្បូនាមានការនិយមខ្លាំងបំផុតនៅមុនសម័យអង្គរ តែប្រាសាទប្រភេទនេះមិននិយមទេនៅសម័យអង្គរ។ យើងអាចរកឃើញការសាងប្រាសាទបែបផាម្បូនាដោយកម្រណាស់នៅសម័យអង្គរ ។ ជាក់ស្តែងប្រាង្គកណ្តាលនៃប្រាសាទគុកនគរ មានលក្ខណៈជាប្រាសាទបួនជ្រុងមានសារពើសូត្រ ចំណែកដំបូលមានលក្ខណៈជាដំបូលសំប៉ែតត្រួតគ្នាច្រើនជាន់ តាមជាន់នីមួយៗនៃដំបូលមិនមានការលម្អទ្វារបញ្ឆោត សសរពេជ្រ ផ្តែរ ឬបាំងក្លែងឡើង ខុសប្លែកពីលក្ខណៈទូទៅនៅប្រាសាទសម័យអង្គរ។ ការធ្វើដំបូលត្រួតគ្នាច្រើនជាន់បែបនេះបង្ហាញពីលក្ខណៈរបស់ប្រាសាទបែបផាម្បូនា។ តែអ្វីដែលវិវត្តថ្មីនៅសម័យនេះគឺ មិនមានការលម្អគូឌុនៅតាមជាន់នីមួយៗនៃដំបូលទៀតហើយ (រូបលេខ២៥)។



រូបលេខ២៥៖ ប្រាសាទគុកនគរ (រូបថត៖ http://bruno.tredez.com/)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

សរុបមកប្រាសាទបែបផាម្សនាជាទម្រង់ប្រាសាទមួយប្រភេទដែលខ្មែរទទួលឥទ្ធិពលពីសិល្បៈឥណ្ឌានៅមុនសម័យអង្គរ។ ក្នុងពេលជាមួយគ្នាខ្មែរបានអភិវឌ្ឍទម្រង់ប្រាសាទនេះឱ្យមានលក្ខណៈពិសេសជារបស់ខ្មែរស្របតាមរសនិយមបែបខ្មែរ។

## បញ្ជីឯកសារយោង


ព្រាប ចាន់ម៉ារ៉ា.

២០១២. *ពាក្យប្រើចំពោះសំណង់បុរាណនិងក្បាច់លម្អ*, ភ្នំពេញ។

ឡេង ស៊ីវ៉ង់.

២០២២. https://ams.com.kh/khmercivilization/detail/20468

Hardy, Adam.

2007. *The Temple Architecture of India*, Chichester: Wiley.

Tingsanchali, Chedha.

2022. *Temple in Southeast Asia*. Matichon, Bangkok.


AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់